# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ១០៤១ ព.ណ.ន.ផពកព

ថ្ងៃ អង្គារ ៦កើត ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០២៦

## សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក-លោកស្រី ដែលជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជនទូទៅឱ្យបានជ្រាបថា ក្រសួងពាណិជ្ជកម្មនឹងសហការគាំទ្រសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) ក្នុងការរៀបចំព្រឹត្តិការណ៍ «**នគរសង្ក្រាន្ត**» ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៤-១៩ ខែមេសា ឆ្នាំ២០២៦ រាជធានីភ្នំពេញ។ ព្រឹត្តិការណ៍នេះ រៀបចំឡើងក្នុងគោលបំណងបង្ហាញនូវអត្តសញ្ញាណជាតិខ្មែរតែមួយ ពង្រឹងភាពរួបរួមសាមគ្គីរបស់ប្រជាជាតិកម្ពុជាជាធ្លុងមួយ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាជំរុញចលនាសេដ្ឋកិច្ចក្នុងស្រុក ជាពិសេសគឺការផ្សព្វផ្សាយពីភាពវិជ្ជមាន និងភាពធន់របស់កម្ពុជាទៅកាន់ពិភពលោក ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។

ព្រឹត្តិការណ៍ «**នគរសង្ក្រាន្ត**» នឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៤-១៩ ខែមេសា ឆ្នាំ២០២៦ នៅតំបន់ស្ពាននាគ តំបន់ផ្លូវថ្មើរជើងចតុមុខ តំបន់វត្តភ្នំនិងប្រៃសណីយ៍កម្ពុជា តំបន់សួនមុខវត្តបទុមវត្តី តំបន់កោះពេជ្រ បណ្តោយមហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ និងកម្មវិធីអមដែលគ្រោងនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១១-១៩ ខែមេសា ឆ្នាំ២០២៦ នៅតំបន់ផ្សារទួលទំពូង និងតំបន់បាសាក់លែន រាជធានីភ្នំពេញ ដែលក្នុងនោះ ក្រសួងពាណិជ្ជកម្ម នឹងចូលរួមរៀបចំពិព័រណ៍ផលិតផលខ្មែរអមព្រឹត្តិការណ៍ខាងលើ។

ក្នុងន័យនេះ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញ លោក-លោកស្រី ដែលជាពាណិជ្ជករ ផលិតករ វិនិយោគិន និងសាធារណជនទូទៅ ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមក្នុងព្រឹត្តិការណ៍ពិព័រណ៍ខាងលើ សូមទំនាក់ទំនងមកនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម តាមរយៈអាសយដ្ឋាន៖ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ តាមរយៈទូរសព្ទលេខ +៨៥៥ ៩៥ ៣២៣ ៩៦៧/+៨៥៥ ៩៧ ៦០៩ ០៦៥០ ឬតាមរយៈអ៊ីម៉ែល៖ chao.katphuoy@moc.gov.kh/sorn_pitou@yahoo.com៕

សម្រាប់ចុះឈ្មោះ

GO.gov.KH

សូមអរគុណ!

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

# ពាក្យសុំចុះឈ្មោះចូលរួម
## ពិព័រណ៍ផលិតផលខ្មែរ អមព្រឹត្តិការណ៍ «នគរសេរីខ្មែរ»

រាជធានីភ្នំពេញ ថ្ងៃទី១៤-១៩ ខែមេសា ឆ្នាំ២០២៦

### ១.ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ........................................................................................ |
| ឈ្មោះប្រធានក្រុមហ៊ុន | ........................................................................................ |
| អាសយដ្ឋានក្រុមហ៊ុន | ........................................................................................ |
| ទូរស័ព្ទ | ........................................................................................ |
| អ៊ីម៉ែល | ........................................................................................ |

### ២.ព័ត៌មានអំពីប្រភេទផលិតផល

| ប្រភេទផលិតផល | | រាយមុខផលិតផល |
|---|---|---|
| កសិផល | ☐ | ........................................................................................ |
| ជលផល | ☐ | ........................................................................................ |
| ម្ហូបអាហារ-ភេសជ្ជៈ | ☐ | ........................................................................................ |
| ផលិតផលសិប្បកម្ម | ☐ | ........................................................................................ |
| ផលិតផលឧស្សាហកម្ម | ☐ | ........................................................................................ |
| វត្ថុអនុស្សាវរីយ៍ | ☐ | ........................................................................................ |
| ផ្សេងៗ..... | ☐ | ........................................................................................ |

### ៣-លក្ខខណ្ឌនៃការចូលរួម

-ត្រូវរៀបចំស្តង់របស់ខ្លួនឱ្យបានរួចរាល់មួយថ្ងៃ មុនពេលបើកសម្ពោធពិព័រណ៍

-មិនអនុញ្ញាតឱ្យតាំងបង្ហាញ/លក់ផលិតផលផ្សេង ដែលមិនមានបំពេញនៅក្នុងបែបបទខាងលើ

-មិនអនុញ្ញាតផ្ទេរស្តង់ ឬទុកស្តង់ឱ្យនៅទំនេរក្នុងរយៈពេលនៃការតាំងពិព័រណ៍

ក្នុងករណីមិនបានអនុវត្តតាមការណែនាំខាងលើ គណៈកម្មការមានសិទ្ធិបិទស្តង់ ឬដកហូតស្តង់មកវិញ ហើយរាល់ការចំណាយសាងសង់ស្តង់ជាបន្ទុករបស់ម្ចាស់ស្តង់។

ខ្ញុំបាទ/នាងខ្ញុំ ជាប្រធាន/តំណាងក្រុមហ៊ុន សូមធានាអះអាងថា ព័ត៌មានខាងលើពិតជាត្រឹមត្រូវពិតប្រាកដមែន និងសូមអនុវត្តតាមលក្ខខណ្ឌនៃការចូលរួមខាងលើ។ បើខុសពីការពិត ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៦

**ប្រធាន/តំណាងក្រុមហ៊ុន**

ហត្ថលេខា និងត្រា